កិច្ចសម្ភាសរបស់លោកសៈ យ៉ោះ តង

ក៖ អ្នកសំភាសលោក៖ ថន រដ្ឋា   ខ៖ អ្នកផ្ដល់ការសម្ភាសលោក៖ យ៉ោះ តង

បាទនៅថ្ងៃនេះគឺថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩។ ហើយខ្ញុំបាទឈ្មោះ ថន រដ្ឋា គឺជាក្រុមការងាររបស់គម្រោងប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា។ ហើយគម្រោងហ្នឹងត្រូវបានគាំទ្រដោយសកលវិទ្យាល័យមួយហៅថា BYU នៅសហរដ្ឋអាមេរិកផងដែរ។ ហើយគម្រោងនេះបើទៅកាន់វែបសាយមួយដែលមានឈ្មោះថា៖ www.cambodiaoralhistory.edu.byu.

ហើយថ្ងៃនេះខ្ញុំមកជួបមានដែលរស់នៅក្នុភូមិទទឹងថ្ងៃឃុំឬស្សីលោក ស្រុកជីក្រែង ខេត្តសៀមរាបគឺមាយោះ តង ហើយឥឡូវមានអាយុអាយុប៉ុន្មានហើយមាន មាអាយុហាសិបប្រាំពីរណ៎ មានសូមជួយជម្រាបឈ្មោះពេញម្ដងទៀតមាន?

ខ៖ ឈ្មោះខ្ញុំយោះ តង យោះតង។

ក៖ យោះ តងណ៎? មាននាមឈ្មោះហៅក្រៅទេ?

ខ៖ អត់មានផង។ មានដែរគេហៅអាប៉ាន់ៗ ឈ្មោះនោះមិនងាយទេ ទាល់តែគ្នាឯងមិត្តភក្តិហៅលេង បើសម្រាប់អ្នកស្រុក គេហៅតាតង។

ក៖ កាលពីនៅក្មេងមា មានឈ្មោះអ្វីផ្សេងទេ?

ខ៖ អត់ផង អត់មានទេ។ អត់មានឈ្មោះអីផ្សេងទេ មានតែនៅរៀនក៏តង ចាស់ហើយក៏តងនោះឯង តងតែទាំងអស់នោះ។

ក៖ ចុះឈ្មោះប៉ាន់គេចាប់ហៅតាំងពីកាលណាមក?

ខ៖ អញ្ចឹងទាក់ទងនឹងស្រុកកំណើតរបស់មាននៅឯណាដែរ?

ក៖ ស្រុកកំណើតកើតនៅនឹងនេះដែរ

ខ៖ កាលណោះវាឈឺ ឈឺហើយវាស្គម ដល់ស្គមទៅវាដូចអាប៉ិកប៉ាន់ពីរ អង្កាលគេជម្លៀសមកពីសម័យដាច់ចិតប្រាំ គាត់មកនៅភូមិនេះឯង ស្គមដូចគាត់ហើយក៏

គាត់ណោះឈ្មោះប៉ាន់ ក៏ហៅតាមឯងស្គមដូចគាត់ក៏ហៅថាប៉ាន់ៗ

បានម៉ាហ៊ីទៅក៏ឈប់ហៅនូវចាស់ៗម្នាក់ម្នាក់ទៅ

ខ៖ អានោះពីកាលឈឺ កាលឈឺទៅវាស្គម ដល់ស្គមទៅវាដូចអាប៉ិប៉ាន់

អាអង្កាលគេជំលៀសមកកាលពីសម័យ ដាច់ចិតប្រាំ ហើយគាត់មកនៅភូមិនេះឯង

ទៅក៏ស្គមដូចគាត់ឯង គាត់នោះឈ្មោះប៉ាន់ គេហៅតាម ឯស្គមដូចគាត់គេហោះប៉ាន់ៗ

បានមួយហឹទៅគេឈប់ហៅ នៅចាស់ៗ ម្នាក់ម្នាក់ទៅគេហៅ។

ក៖ អញ្ចឹងទាក់ទងនឹងស្រុកកំណើតរបស់មានៅឯណាវិញដែរ?

ខ៖ ស្រុកកំណើតនៅហ្នឹងនេះឯង។

ក៖ ភូមិអីឃុំអី ស្រុកអី?

ខ៖ ពីដើមគេអត់ទាន់កាត់ចូលទទឹងថ្ងៃទេ មានមេភូមិ ផ្សេងៗគ្នា គេហៅភូមិលាងពុង

ឃុំឬស្សីលោក អានេះវគ្គក្រោយណាស់ វាមានមុននោះឯទៀត

ដល់បន្ទាប់មកបានភូមិលាងពុងឃុំសង្វើយ ទើបតែបំបែកពីឬស្សីលក បន្ទាប់ពីសង្វើយ

គេដាក់ឃុំឬស្សីលោកអញ្ចឹង។

ក៖ ភូមិទទឹងថ្ងៃ ឃុំឬស្សីលក?

ខ៖ ភូមិទទឹងថ្ងៃឃុំឬស្សីលោក លាងពុងបាត់ហើយ មេភូមិទាំងអស់គ្នា ទាំងទទឹងថ្ងៃ

ទាំងលាងពុង ភូមិតែមួយទេ។

ក៖ ទាក់ទងនឹងភាសារក្រៅពីភាសាខ្មែរ តើមាអាចនិយាយភាសារអីបានទេ?

ខ៖ ងត់ចេះផង។

ក៖ មាចេះនិយាយភាសារអង់គ្លេសទេ?

ខ៖ អត់ទេ អត់ចេះទេ។

ក៖ ចុះភាសារថៃ?

ខ៖ ភាសារថៃក៏អត់ចេះ ថាចេះមេចកើត បើនិយាយអត់ចេញ អត់ចេះទេ។

ក៖ ទាក់ទងនឹងភាសារខ្មែរ មាអាចអានបានសរសេរបានទេ?

ខ៖ អានបានខ្លះ សរសេរបានខ្លះ ប៉ុន្តែវា មិនដូចគេសព្វថ្ងៃទេ បុរាណ្យ បុរាណ បានតិចតួច ស្គាល់ខ្លះ បានតិចតួចដែរ រៀនសម័យនោះយើងអត់មានថ្នាក់ មានអីទេ រៀនទាល់តែធំមិនដឹងជាឡើងថ្នាក់ទៅឯណាទៅឯណីទេ ទាល់តែធំ រៀននៅដើមឈើខ្លះ ក្រោមផ្ទះខ្លះ ក្នុងសាលាក្នុងព្រៃខ្លះ អត់ដែលបានរៀនល្អល្អិតទេ មិនដឹងថ្នាក់ទីប៉ុន្មាន ទីប៉ុន្មានទេ អត់ដឹងទេ អាធំគេដាក់តាមធំ អាតូចគេដាក់តាមតូច អាចចេះរៀនទៅខ្ញុំសង្ខាតក្រោយៗមកទៀត ដែលវៀតណាមចូលមកចូលសាលាបានមួយថ្ងៃពីរថ្ងៃ មើលទៅមិនកើតទេធំផង ទ្រើគ្រាន់ដែរឈប់រៀនតាមផ្ទះបន្តិចបន្តួច យប់ឡើងគេបង្កាត់បន្តិចបន្តិចទៅបានចេះខ្លះហើយ បន្ទាប់បន្ទំវាមិនអាវធ្វើការងារអីកើតទេ នៅមើលបានអានបាន ប៉ុណ្ណោះឯង។

ក៖ អញ្ចឹងបច្ចុប្បន្ននេះមារស់នៅភូមិណា ឃុំណា ខេត្តណា?

ខ៖ បច្ចុប្បន្នរស់នៅទទឹងថ្ងៃ ឃុំឬស្សីលកស្រុកជីក្រែងខេត្តសៀមរាប។

ក៖ ប្រពន្ធរបស់មាឈ្មោះអី?

ខ៖ គេហៅប្រេនតុងឈិន។

ក៖ ពូជចិន?

ខ៖ អត់ទេ ខ្មែរដែរ ប៉ុន្តែ ពុកគេស្រឡាញ់ចេះតែដាក់ទៅណាស់ អោយវាឡូយទៅ។

ក៖ អញ្ចឹងរយៈពេលប៉ុន្មានហើយដែលមារៀបការជាមួយមីង?

ខ៖ តាំងពីរប៉ែតបី ប៉ែតបីមមាញឹកច្រណាប់ ថវិការមានភាគីមាចំហៀង ពលពត បន្ទាបើមកបានខ្មែរយើង ខាងក្នុង គេហៅខាងក្នុងខាងក្រៅ កាលណោះពិបាកវៀតនាដែរ

ពិបាកសែនប្រេន យកអង្ករយកសាច់ទៅប្រគៀនគេ បានគេអត់ទៅបៀតរោងការ

លំបាកណាស់លំបាកតែមែនទែនណាស់ ទំរាំនឹងការកើតនោះ ភ្នែកសរភ្នែកខ្មៅ។

ក៖ គេអត់ចង់អោយការ?

ខ៖ គេអោយការដែរ តែគេប្រឆាំង គេថាបើគេមិនធ្វើអញ្ចឹងអត់បានអីហូប

ដើរទៅក្រផែលៗទៅសែនគេ ទើបគេដើរទៅឆ្ងាយ សុទ្ធតែសែនគេណា៎។

ក៖ អញ្ចឹងកាលណោះ អ្នកណាជាអ្នករៀបចំ រៀបចំកម្មវិធីការនោះ

មាស្គាល់គកនាប៉ុន្មានឆ្នាំទើបបានរៀបការជាមួយគ្នា?

ខ៖ ស្គាល់គ្នាយូរហើយ ស្រុកកំណើតកើតជាមួយគ្នា។

ក៖ តាំងពីតូចក្រូចឆ្មារមក?

ខ៖ តាំងពីរតូចក្រូចឆ្មាមក ស្គាល់ម៉ែស្គាល់ឪ ស្គាល់ដល់ទៅតាទៀតនោះ

មិនត្រឹមតែស្គាល់ដល់ម៉ែឪគេទេ ស្គាល់ដល់ទាំងតាគេទៀត អាចទុកចិត្តបានបានហ៊ានយក។

ក៖ អញ្ចឹងបានន័យថា មុននឹងរៀបគ្នាជាគូរ កាលយកគ្នាជាគូរ ស្គាល់គ្នាពីក្មេងហើយ

ស្គាល់គ្នាដល់ឪពុកម្ដាយទៀតណ៎?

ខ៖ ឪពុកក្មេកមិនទាន់ដល់ឪពុកបង្កើត គឺឪពុកបង្កើតមិនដូរ ដើរតែជាមួយគាត់ ភ្ជួរដី

ភ្ជួរស្រែភ្ជួររាស់ធ្វើស្រែជាមួយគាត់។ គាត់កស្គាល់ចិត្តខ្ញុំ ខ្ញុំក៏ស្គាល់ចិត្តគាត់

ស្គាល់ទៅវិញទៅមកទាំងអស់គ្នា។

ក៖ ទាក់ទងនឹងបណ្ណាការតើនរណារៀបអោយ?

ខ៖ ម្ដាយ។

ក៖ ប៉ុន្មាន? អំអស់ប៉ុន្មានបណ្ណាការកាលណោះ?

ខ៖ អស់ម៉ាម៉ឺន អស់ប្រាំបួនពាន់ ប្រាំបួនពាន់ប្រាក់ខ្មែរយើងកាលណោះ

ចាយមួយកាក់ពីរកាក់នោះ ថ្លៃដែរប្រាំបួនពាន់ បើគឹតទៅរាប់តំលឹងដែរ ចង់ថាតំលឹង?

ក៖ ជិតមួយម៉ឺន?

ខ៖ បាទ ជិតមួយម៉ឺន។

ក៖ ប៉ុន្តែមួយវាស្មើរនឹងឥឡូវនេះមួយម៉ឺនត្រូវទេ?

ខ៖ មិនដឹងដែរកាលណោះថ្លៃដែរ។

ក៖ បើមួយរយស្មើរហឹង?

ខ៖ មួយកាក់ស៊ីនំអាកោហាល់ ទិញតែប្រាំបាក់ហូរចំភ្ញុះ។

ក៖ អញ្ចឹងមូលហេតុអីបានជាមា សម្រេចចិត្តរៀបការនឹងមីង?

ខ៖ មូលហេតុខ្ញុំស្រឡាញ់គេ ម្តាយគាត់ថារៀបការយកគ្រួសារទៅ ចាស់គេពិនិត្យ

គេស្រឡាញ់ក៏យកទៅ។

ក៖ ចុះស្រឡាញ់គាត់ត្រង់ណា?

ខ៖ ស្រឡាញ់ត្រង់ណា ស្រឡាញ់ទាំងគ្រួសារគាត់ ស្រឡាញ់ទាំងអស់នឹងរស់នៅបាន។

ក៖ ស្រឡាញ់គ្នារហូតមែន?

ខ៖ មានអីស្រឡាញ់រហូតតើ។

ក៖ នោះគាត់ថាស្រឡាញ់គ្នារហូតតើ?

ខ៖ វាមានប៉ះទង្គិចគ្នាបន្តិចបន្តួច វាមានទៅណា ដ៏ដែលៗវាប៉ុណ្ណឹងទៅហើយ មានទៅណាទៀត

ទៅស្រីក្មេងក្រែងគេបោកយើង នោះហើយក៏នៅជាមួយយាយចាស់នេះទៅ។

ក៖ គេថាកាលពីក្មេងស្រឡាញ់គ្នាម្តង ចាស់កោងខ្នងស្រឡាញ់គ្នាម្តងទៀត។

ខ៖ ត្រូវហើយបណ្តើគ្នារាល់ថ្ងៃ។

ក៖ បណ្តើររាល់ថ្ងៃ?

ខ៖ ទៅសុំសិលទៅស្វូត្រធម៌អី បណ្តើរាល់ថ្ងៃ រាល់តែយប់សៀវភៅមួយៗម្នាក់។

ក៖ ទៅជាមួយគ្នាទៀត?

ខ៖ ទៅជាមួយគ្នាទៀត។

ក៖ អេមហើយអញ្ចឹងនោះ។

ខ៖ ស្ងួត្រធម៌រាល់តែថ្ងៃ។

ក៖ ទាក់ទងនឹងបងប្អូនមានជាកូនទីប៉ុន្មាននៅក្នុងក្រុមគ្រួសារ?

ខ៖ ពៅគេ។

ក៖ មាមានបងប្អូនប៉ុន្មានអ្នក?

ខ៖ បងប្អូន មានដែលឃើញមុខបីនាក់។

ក៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ខ៖ ប្រុសទាំងបី។

ក៖ ចុះអ្នកផ្សេងទៀត មេចអត់ឃើញមុខអញ្ចឹង?

ខ៖ អ្នកផ្សេងម៉ែថាមានម្នាក់ម៉ែថា មងាប់តាំងពីតូច ខ្ញុំអត់ដឹងដែរ ឃើញមុខឃើញតែបីនាក់។

ក៖ មាសូមជួយជម្រាប់ឈ្មោះរបស់មា តើគាត់ឈ្មោះអ្វីហើយកើតនៅឯណា?

ខ៖ បងប្ងូនបងគេទីមួយ?

ក៖ បាទ។

ខ៖ បងទីមួយកើតនៅភូមិបត់តាកោ។

ក៖ បត់តាកោឃុំអី?

ខ៖ កាលណោះឃុំអីកទេ ឃុំសំរោង ឃុំត្បែកទេ ទេឃុំសំរោងនោះ កើតនៅឃុំសំរោង។

ក៖ ស្រុក?

ខ៖ ស្រុកសូទ្រនិគមន៍។

ក៖ ខេត្តសៀមរាប?

ខ៖ ខៀតសៀមរាបយើង។

ក៖ ហើយគាត់ប្រកបការងារអីដែរ?

ខ៖ អូ គាត់អត់មានប្រកបការងារអីទេ ធំទៅគេយកទៅធ្វើទាហ៊ាន ធ្វើទាហ៊ានប៉ុលពោតយូរហើយតាំងពីចិត្តមួយចិត្តពីរ គាត់ធ្វើទៅក៏វាបាត់គាត់នោះឯង បាតលោះសព្វថ្ងៃនេះឯង ចិតប្រាំរំដោះរួចគាត់មកដល់ផ្ទះ ទេចិតបួនហ្នឹងឯង រំដោះបាត់ចិតបួនឃើញគាត់។

ក៖ ឃើញគាត់ប៉ុន្មានខែ?

ខ៖ គាត់មកលែងផ្ទះ មិនមកលែងយូរទេ បានប្រហែលជាប្រាំប្រាំមួយឆ្នាំគាត់ក៏មកលែងវិញ ដល់ទៅវិញដាច់ចិតប្រាំ ដាច់ចិតប្រាំសួរគេសួរឯងថានៅតើ? នៅស្រាប់តែឆេះឃ្លាំងគ្រាប់នៅសៀមរាប គាត់មេគេដែរ មេមិនធំទេ គ្រាន់តែបន្ទាប់បន្ស៊ំ ដល់ពេលទៅផ្ទុះឃ្លាំងគ្រាប់គេថាឯងខ្មែរឯណា ឯណី គេចាប់សម្លាប់ចោលហើយដឹងបាត់តាំងពីត្រឹមណើឯងណា។

ក៖ គ្រាន់តែបាត់ទេណោះ?

ខ៖ នោះឯង។

ក៖ ចុះបងប្អូនទីពីរវិញឈ្មោះអ្វីដែរ?

ខ៖ ឈ្មោះ យ៉ោះ ហ៊ីង។

ក៖ គាត់បច្ចុប្បន្ននៅឯណា?

ខ៖ បច្ចុប្បន្ននៅអូរផ្អៅ។

ក៖ គាត់ស្រីប្រុស?

ខ៖ ប្រុស។

ក៖ គាត់មានប្រពន្ធហើយនូវ?

ខ៖ មានហើយ។

កៈ ពួកគាត់ទាំងពីរអ្នកមានកូនប៉ុន្មានហើយ?

ខៈ កូនគាត់ ក្រែគ្រាន់ដែរ កូនគាត់ ប្រាំពីរ។

កៈ ប្រាំពីរនាក់ណ៎?

ខៈ កូនអ៊ំហឹងប្រាំពីរអីមេផាន់? អេក្រែលឯណាស់ ប្រាំពីរ។ ចាំមើលណាស់ ក្រហាប់ ក្រហើម ក្រហ៊ាន់ ក្រហៃ ផ្គោក សរ ប្រាំពីរ។

កៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ខៈ ស្រីពីរប្រុសប្រាំ។

កៈ ចុះបងប្អូនទីបីនោះ?

ខៈ ទីបីខ្ញុំ។

កៈ ចូលដល់បងប្អូនទីបួនវិញម្តង។

ខៈ អត់មានទីបួន មានតែទីបី។

កៈ អញ្ចឹងមានតែបីនាក់ទេណ៎?

ខៈ មានតែបីនាក់ទេ។

កៈ អញ្ចឹងក្មួយមានប៉ុន្មានហើយ?

ខៈ ក្មួយខាងណា?

កៈ ខ្មួយខាងមា?

ខៈ មានប្រាំពីរនាក់ប៉ុណ្ណោះឯង បងអត់មានគ្រួសារទេ នៅខាងខ្ញុំមានតែប្រាំពីរនាក់ប៉ុណ្ណោះឯង នៅខាងគេបានច្រើន ច្រើនណាស់។

កៈ អញ្ចឹងទាក់ទងនឹងឪពុកម្តាយ នឹងជីដូនជីតាវិញម្តង តើម្តាយរបស់មាឈ្មោះអី?

ខៈ ឈ្មោះតាយ៉ោះ។

កៈ តាយ៉ោះគាត់ស្រុកកំណើតនៅឯណា?

ខ៖ នៅអូររលួស អូរលួសខាងលើដំដែក។

ក៖ បាទ។ ហើយគាត់អាយុប៉ុន្មានហើយ?

ខ៖ អូស គាត់ស្លាប់តាំងពីរអាយុ ចិតបី ចិតបីចិតបួន ចិតបី ចិតប៉ុន្មាន ចិតគត់ ចិតគត់ទេដឹង មើលតែស្រុករត្នប្រហា គាត់ខូចហើយ ចិតមួយ ចិតអីនោះឯង ចិតមួយ ថាចិតមួយទៅ ចុះគាត់មានបងប្អូនប៉ុន្មាននាក់មា បងប្អូនខ្មោចចិ បងប្អូនគាត់ បងប្អូនគាត់បួននាក់។

ក៖ បួននាក់ស្រីកប៉ុន្មាន ប្រុសប៉ុន្មាន?

ខ៖៖ ស្រីមួយប្រុសបី។

ក៖ មិញខ្ញុំជំរាប់សួរទាក់ទងនឹងបងប្អូនខាងម្តាយ ទាក់ទងនឹងឪពុកខាងម្តាយវិញ បងប្អូនខាងម្តាតឈ្មោះអី?

ខ៖ ខាងម្តាយខ្ញុំ?

ក៖ បាទ។

ខ៖ សួរឈ្មោះបងប្អូនគាត់?

ក៖ បាទអញ្ចឹងក៏បាន។

ខ៖ ឬក៏សួររឿងប៉ុន្មាននាក់ ប៉ុន្មាននាក់?

ក៖ បងប្អូនខាងខាងម្តាយ មានប៉ុន្មាននាក់?

ខ៖ បងប្អូនខាងម្តាយក៏តិចដែរ បេង ថង បួននាក់ដែរ។

ក៖ អញ្ចឹងប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ខ៖ ប្រុសពីរ ស្រីពីរ។

ក៖ ជីដូនជីតាខាងម្តាយបានជម្រាបខ្ញុំហើយនៅ?

ខ៖ នៅ។

ក៖ គាត់ឈ្មោះអី?

ខ៖ មាយឈ្មោះយាយយ៉ាត់ យាយយ៉ាត់តាយ៉ោះ។

ក៖ ចុះខាងឪពុក?

ខ៖ ខាងឪពុកខ្ញុំឈ្មោះតាយ៉ោះ ម្ដាយខ្ញុំឈ្មោះយាយយ៉ាត។

ក៖ បាទ។

ខ៖ យាយយ៉ាត់គាត់មានឪពុកម្ដាយ របស់គាត់ឈ្មោះអី?

ក៖ ឈ្មោះយាយខ្លោក។

ខ៖ តាប៊ិន។

ក៖ ចុះតាខាងម្ដាយឈ្មោះអី?

ខ៖ តាខាងឪពុក?

ក៖ បាទ។ តាយាយខាងឪពុក?

ខ៖ អូរ ឈ្មោះ យាយសៀត តាអីអញ្ចេះ? រកនឹងសិន យាយផាន់តាអីអញ្ចឹង អាដោយហ្នឹងតែងដាក់ត្រគោល ស្គាល់ដរប៉ុន្តែភ្លេច?

ក៖ យាយសៀត?

ខ៖ យាយសៀតនោះឯង ដឹងតាអីទេ?

ក៖ រក្សាទុកអោយកូនចៅ?

ខ៖ តាអ៊ុនរអីកាផាន់ តាអ៊ុនអញ្ចឹងឯង?

ក៖ ដើម្បីរក្សាទុកអោយកូនចៅជំនាន់ក្រោយ។

ខ៖ តាអ៊ុន ឈ្មោះតាអ៊ុន។

ក៖ ឈ្មោះតាអ៊ុនណ៎?

ខ៖ នោះឯង។

ក៖ ពួកគាត់ស្រុកកំណើត នៅឯណាដែរ?

ខ៖ ខាងថ្ម ចិកនៅ ស្រុកកំណើតតានៅ មិនដឹងនៅឯណាទេ

បើស្រុកកំណើតយាយហនៅថាកំពុងថ្កូវ នៅទៅក្រោម។

ក៖ អញ្ចឹងបើ មាមានបងប្អូននៅក្រៅប្រទេសទេ?

ខ៖ អតវ់ផងមានតែ អត់មាន។

ក៖ អត់មានទេណ៎? តើមានាមកូនប៉ុន្មាននាក់ហើយសព្វថ្ងៃ?

ខ៖ មានប្រាំបីនាក់។

ក៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ខ៖ ស្រីប្រាំ ប្រុសបី។

ក៖ អ្នកទីមួយគាត់ឈ្មោះអី?

ខ៖ អ្នកទីមួយឈ្មោះ ញ៉ៀវ។

ក៖ គាត់អាយុប៉ុន្មានហើយ?

ខ៖ អាយុប៉ុន្មានជីតសាបហើយដឹង សាមបី អឺ សាមបីហើយ។

ក៖ គាត់ប្រកបមុខរបរអីដែរ?

ខ៖ ស្រែចំការ។

ក៖ ញ៉ៀវគាប្តី ហើយនូវ?

ខ៖ មាន។

ក៖ ប្តីគាត់ឈ្មោះអី?

ខ៖ គាត់ឈ្មោះ វ៉ាន់។

ក៖ ចុះកូនទីពីរឈ្មោះអីដែរ?

ខ៖ កូនទីពីរ មីណាក់។

ក៖ មីណាក់ស្រី ឬប្រុស?

ខ៖ ស្រី។

ក៖ គាត់អាយុប៉ុន្មាន?

ខ៖ អាយុសាមហើយ សាមមួយហើយ។

ក៖ ហើយណាក់គាត់មានប្តីអត់?

ខ៖ មានតា។

ក៖ ប្តីគាត់ឈ្មោះអី?

ខ៖ ឈ្មោះ ប៉ារីស។

ក៖ អញ្ចឹងពួកគាត់ទាំងពីរនាក់បានកូនប៉ុន្មាន?

ខ៖ កូនពីរ។

ក៖ ប៉ារីសនៅណា?

ខ៖ នៅនេះតា។

ក៖ ស្រុកកំណើត?

ខ៖ នៅទទឹងថ្ងៃ។

ក៖ ហើយទីបី កូនទីបីឈ្មោះអីមា?

ខ៖ តង ងូ។

ក៖ តង ងូណ៎? ហើយគាត់អាយុប៉ុន្មានហើយ?

ខ៖ អាយុ២០ហើយ។

ក៖ គាត់មានស្វាមីនៅ?

ខ៖ មាន។

ក៖ ហើយគាត់មានកូនប៉ុន្មានហើយ?

ខ៖ កូនមួយ។

កៈ ឈ្មោះអីដែរ?

ខៈ កូនឈ្មោះ ទីណា។

កៈ អ្នកទីបួនគាត់ឈ្មោះអីដែរ?

ខៈ ឈ្មោះ តង ខៅ។

កៈ តង ខៅ?

ខៈ អ៊ឺ!

កៈ ហើយគាត់អាយុប៉ុន្មានហើយ?

ខៈ អាយុ២០ ២៥ហើយដឹង! អាយុ២៧។

កៈ គាត់មានគ្រួសារហើយនៅ?

ខៈ មានហើយ។

កៈ ចុះកូន?

ខៈ កូនមួយ។

កៈ កូនមួយ?

ខៈ ហ៊ឺ!

កៈ ចុះបងប្អូនទីបួនឈ្មោះអី?

ខៈ ទីបួនរួចហើយ។

កៈ ទីប្រាំអញ្ចឹង?

ខៈ ទីប្រាំឈ្មោះ ទូច! តង ទូច។

កៈ ទូច! ស្រី ឬប្រុស?

ខៈ ស្រី។

កៈ ប្ដីគាត់ឈ្មោះអី?

ខ៖ អត់មាន។

ក៖ គាត់អត់ទាន់មានគ្រួសារទេ?

ខ៖ អរ! ប្ដីមានហើយទូច, ប្ដីគាត់ឈ្មោះ អារុម, ឈ្មោះ រុម។

ក៖ ឈ្មោះ រុម?

ខ៖ ហ៊ឺ!

ក៖ ពួកគេទាំងពីរមានកូនប៉ុន្មាន?

ខ៖ អត់ផង។

ក៖ អត់ផង មិចអញ្ចឹង?

ខ៖ ទើបតែបាន។

ក៖ អរ! ចុះកូនទីប្រាំមួយឈ្មោះអី?

ខ៖ កូនទីប្រាំមួយឈ្មោះ ទីន! តង ទីន។

ក៖ តង់ ទីន! ហើយទីនស្រី ឬប្រុស?

ខ៖ ស្រី។

ក៖ ហើយគេអាយុប៉ុន្មានហើយ?

ខ៖ អាយុ ២២។

ក៖ ហើយគាត់មានគ្រួសារនៅ?

ខ៖ អត់!

ក៖ ហើយគាត់ធ្វើអី? ឥឡូវ?

ខ៖ ស៊ីឈ្នួលគេ! ធ្វើរោងចក្រ។

ក៖ បាទ! បន្ទាប់ពីទីនហើយ អ្នកណាគេ?

ខ៖ បន្ទាប់ពីទីន តង ចុង។

កៈ តង ចុង គាត់មានគ្រួសារនៅ?

ខៈ នៅ!

កៈ គាត់នៅលីវដែរ?

ខៈ អ៊ឺ! នៅរៀន។

កៈ នៅរៀនណ៎?

ខៈ ហ៊ឺ! រៀន។

កៈ រៀនថ្នាក់ទីប៉ុន្មាន?

ខៈ ថ្នាក់ទីដប់មួយ។

កៈ ថ្នាក់ទីដប់មួយ រៀននៅណា?

ខៈ រៀននៅ សុគន្ធភាព។

កៈ អញ្ចឹងជិតចប់ហើយណ៎?

ខៈ ហ៊ឺ!

កៈ បញ្ចប់ទីដប់មួយ ចូលទីដប់ពីរ ហើយចូលរៀនទៅកន្លែងផ្សេងទៀត បានទៀតណ៎?

ខៈ ហ៊ឺ!

កៈ ហើយទីប្រាំពីរឈ្មោះអី?

ខៈ ទីប្រាំបី!

កៈ ប្រាំបីណ៎?

ខៈ ហ៊ឺ! អាសំណាង។

កៈ សំណាងអាយុប៉ុន្មានហើយ?

ខៈ ប៉ុន្មាន! ដប់បួន។

កៈ សំណាងនៅរៀនទេ?

ខ៖ រៀន។

ក៖ រៀនថ្នាក់ទីប៉ុន្មាន?

ខ៖ ទីប្រាំបី។

ក៖ ហើយសំណាងគេរៀននៅមុខណា៎?

ខ៖ ហ៊ឺ!

ក៖ ពេលទំនេរសំណាងចូលចិត្តធ្វើអី?

ខ៖ ពេលណានៅផ្ទះប្រើបន្តិច ឃ្វាលគោ ទៅមើលគោជំនួសបន្តិច មួយភ្លែត។

សព្វថ្ងៃអាចមិនបានទៅរៀនគួរ រៀនអីទេ ទៅឃ្វាលគោហ្នឹងឯង។

ក៖ ចុះទាក់ទងហ្នឹងប្រពន្ធ ប្រពន្ធឈ្មោះអីដែរ?

ខ៖ ប្រពន្ធអូ! ប្រពន្ធរបស់អាសំណាង?

ក៖ ប្រពន្ធរបស់មា?

ខ៖ ត្រប់ តុងឈិន។

ក៖ តុងឈិន! ស្រុកកំណើតគាត់នៅណា?

ខ៖ នៅលាងប៉ុងហ្នឹងឯង កើតនៅហ្នឹងឯង។

ក៖ គាត់ប្រកបការងារអីដែរ?

ខ៖ ហ៊ឺ! យាយសព្វថ្ងៃមានធ្វើអីទេ ធ្វើតែស្រែ ចំការដូចខ្ញុំ។

ក៖ កាលពីក្មេងគាត់ចូលចិត្តម្ហូបអី ដឹងទេ?

ខ៖ អត់ដឹងផង! ដឹងគាត់ហូបម្ហូបអី។

ក៖ មិចអញ្ចឹង?

ខ៖ ហ៊ឺ! ពីក្មេងមកទៅដឹងថាគាត់ហូបម្ហូបអី។

ក៖ ចុះធំឡើងគាត់ចូលចិត្តម្ហូបអី?

ខ៖ ធំទៅគាត់ចូលចិត្តម្ហូបស្រែហ្នឹងឯង ស្លរាងច្រើន គេថាឆាប់ធំឯណា ឯណី។

អាសម្លស្រែៗគាត់ដូចជាប៉ុនហូប សម្លប្រហើរ សម្លស្រែអីហ្នឹងទៅ ធម្មតាស្លស្លឹកបាស់ ស្លឹកអី

អាណូងទៅ ចូលចិត្ត។

ក៖ បាទ!

ខ៖ ដូចឆាអី គេថាឈ្ងុយខ្ទឹម ធុមខ្ទឹមឯណា ឯណី! ធុមគាត់ហូបមិនកើត។

ក៖ បាទ! អញ្ចឹងទាក់ទង និងសុខភាពវិញ សុខភាពរបស់មាមិចដែរ?

ខ៖ អរ! សុខភាព វាពិបាកដែរ មិនសូវជាជាប៉ុន្មាន ប៉ុនចេះតែទៅៗ ចេះតែធ្វើៗទៅ

គ្រាន់ទុកចិញ្ចឹមកូន។ ប្រាប់កូនអោយធ្វើការងារ យើងធ្វើមេ ប្រាប់ហើយបើវាមិនធ្វើ

ទៅធ្វើបង្ហាញវាទៅណ៎។

ក៖ បាទ!

ខ៖ ប៉ុហ្នឹងឯង។

ក៖ អញ្ចឹង! ទាក់ទងកីឡា មាចូលចិត្តមើលទេ?

ខ៖ ចូលចិត្តតា ប៉ុនអត់មាន ក៏អត់ទៅ។ បើមាននៅផ្ទះ មើលរាល់តែថ្ងៃ។

ក៖ កាលពីតូចរៀននៅសាលាណា?

ខ៖ ខ្ញុំ!

ក៖ បាទ!

ខ៖ អត់មានសាលាឈ្មោះ គឺសាលាក្នុងភូមិតែប្រដោយ ក្នុងភូមិលាងប៉ុង

តាណារៀននិងដើមឈើទៅ ម្លប់ដើមត្នោតទៅ គេដាក់ក្តារខៀន ក៏រៀនទៅ

ប៉ុនតាណាបានសាលាចូលក្នុងភូមិ ក្រុង តាមផ្ទះទៅ។ ដូចថា ធំដាក់តាមធំ តូចដាក់តាមតូចទៅ

គេប្រាប់មិចទេ ធំដាក់តាមធំ តូចដាក់តាមតូច អត់មានថា អាណាឆ្លាតឡើងថ្នាក់ទៅ អត់ទេ។

ក៖ គេដាក់តាមមាឌណ៎?

ខ៖ ដាក់តាមមាឌ តាមទំហំ អានេះនៅភូមិលាងប៉ុងទេណា៎! បើខុសពីនេះខ្ញុំអត់ដឹង។

ក៖ សម្រាប់តាផ្ទាល់ គិតថាពីមុន និងសព្វថ្ងៃខុសគ្នាទេ?

ខ៖ អូ! ខុសច្រើនណាស់។

ក៖ ខុសមិចទៅ?

ខ៖ ខុសច្រើនត្រង់ការរស់នៅ វាប្លែកច្រើន វាមានផ្លូវថ្នល់ មានគ្រឿងម៉ាស៊ីន គ្រឿងអី

វាចង់ខូចបរិយាកាស។ ហ៊ឺ! លឺពេញវាការ ពីមុនដែលទៅលឺអី មានឡានឯណាមួយ។

ក៖ បាទ!

ខ៖ ប្លែកច្រើនណាស់ តាំងពីហូបចុក មានជាតិគីមីឯណា ឯណឹទៅ ខូចសុខភាព។

សម័យមុនហូបដំឡូងទៅធ្វើការ មានទៅកើតអី រាគ ឈឺថ្កាត់ ក្រពះពោះវៀន ឈឺបេះដូង

ខ្លាញ់រុំឯណា ឯណឹងអត់មានទេ។

ក៖ បាទ!

ខ៖ ពីដើមអត់មានឡាន មានអី។

ក៖ ស្ងប់សុខ?

ខ៖ សុខភាពវាល្អ។ សព្វថ្ងៃវាមានគ្រប់គ្រាន់ វាញាប់ញ៉ឹន និងសុខភាព។

ក៖ បាទ! តើផ្ទះរបស់មា បានសាងសង់រយះពេលប៉ុន្មានឆ្នាំហើយ?

ខ៖ ហ៊ឺ! តាំងពីកៅបី ផ្ទះនេះសាងសង់ពីកៅបី។

ក៖ កៅបីណ៎?

ខ៖ អ៊ឺ!

ក៖ ហើយផ្ទះហ្នឹង ធ្វើពីថ្ម ឬធ្វើពីឈើ?

ខ៖ ជើងវាថ្ម លើឈើ ខាងមុខហ្នឹងតក្រោយទេ។

ក៖ បាទ! សសរធ្វើពីអីតា មា?

ខ៖ ហ៊ឺ! សសរលើឈើ ក្រោមជើងវាថ្មពីស៊ីម៉ង់ ក្រួសខ្សាច់។

ក៖ ចុះដំបូលធ្វើពីអី?

ខ៖ ដំបូលក្បឿងយើង ដីធម្មតា ពីបុរាណ។

ក៖ ចុះចិញ្ចូងធ្វើពីអី?

ខ៖ ក្តារ។

ក៖ ចុះបង្អួច?

ខ៖ ឈើ។

ក៖ ចុះរបងផ្ទះធ្វើពីអី?

ខ៖ របង ក្រាក់។

ក៖ ទំហំដីមាធំទេ?

ខ៖ តូចទេ ដប់ប្រាំពីរ បណ្តោយមិនដឹង អរ! ហុក។

ក៖ ហុកសិបណ៎? របងធ្វើពីអី?

ខ៖ អាហ៊ុមវា បង្គោលវាក្រាក់ ហ៊ុមវាសំណាញ់ដែក។

ក៖ បាទ! ផ្ទះមួយហ្នឹង ធ្វើខ្លួនឯង ឬក៏ជួលជាងធ្វើ?

ខ៖ ជួលគេណា។

ក៖ កាលណោះអស់ប៉ុន្មាន?

ខ៖ អស់ប៉ុន្មានទេ! មួយតម្លឹង មួយតម្លឹងបួនជី មានដុល្លាទេ។

ក៖ ទាក់ទង សត្វចិញ្ចឹមវិញ អូ! ខ្ញុំចងសួរទាក់ទង ជំនាញវិញ មាធ្លាប់ត្បាញវែទេ?

ខ៖ ត្បាញ! អត់មានផង ចេះតែខ្សែគោ ខ្សែគោចេះវិញ អោយត្បាញអត់ចេះវិញ។

ក៖ ធ្លាប់ដាំដំណាំទេ?

ខ៖ ធ្លាប់។

កៈ ដាំដំណាំអីខ្លះ?

ខៈ ពីមុនខ្ញុំដាំឪឡឹក ឪឡឹកស្រូវ ក្រោយមកចន្ទី អំពៅ ឈប់ដាំហើយអំពៅ ដាំតែចន្ទី និងស្រូវនៅសព្វថ្ងៃនេះ។

កៈ បាទ! តាធ្លាប់ចិញ្ចឹមមាន់ ទា ជ្រូក ទេ?

ខៈ ធ្លាប់ចិញ្ចឹម តែលក្ខណៈគ្រួសារ មិនដូចជាក្រុមហ៊ុន ក្រុមអីទេ ខ្លះមួយ ពីរ បីអីទៅ។

កៈ ចុះកូនគោ?

ខៈ គោបង្វាស់បួនប្រាំ ច្រើនណាបួន ដប់ ធ្លាក់មកក្រោមក៏ចែកកូន ចែកចៅទៅបួន ប្រាំទៀតទៅ រួចទៅក៏ចែកកូនអោយគេទៅហ្នឹងដដែលៗទៅ។

កៈ ពូធ្លាប់ឡើងត្នោតពីមុនទេ ពូ?

ខៈ អត់ទេ! អត់ដែលឡើងត្នោត ឡើងអីទេ។

កៈ ធ្លាប់ធ្វើកន្ត្រក់លក់អត់លោកពូ?

ខៈ អត់! អត់ធ្វើអត់ដែលបានធ្វើ បើទ្រូងធ្លាប់ក្រង។

កៈ ធ្លាប់ធ្វើទ្រូងនេសាទត្រីអត់?

ខៈ អរ! នេសាទអីគឺ ក្រងដាក់ហូបលក្ខណៈគ្រួសារ មិនបានយកទៅលក់ ទៅដូរអីទេ។

កៈ បាទ! ចុះទាក់ទងសត្វចិញ្ចឹមសត្វព្រៃវិញ ពូធ្លាប់ចិញ្ចឹមសត្វព្រៃទេ?

ខៈ អត់ផង។

កៈ សត្វសារីកាធ្លាប់ចិញ្ចឹមទេ?

ខៈ ចិញ្ចឹមមួយដង ពីរដងសារីកា ខ្ញុំមិនដែលបានទុកបានយូរ។

កៈ បានប៉ុន្មានឆ្នាំ?

ខៈ អត់ផង! មិនដែលបានដល់ឆ្នាំផង ប្រាំ ប្រាំមួយខែ ប្រាំពីរខែទៅបាត់។

កៈ វាអត់ទាន់បានលឺសំលេងអីទេណ៎?

ខ៖ អត់ទាន់ចេះនិយាយផង គ្រាន់តែកែវហើយ កាក កែវហើយ កាកមិនដឹងថាវាពិបាកឆ្លើយ។ មិនដែលលឺអាកែវហើយបាទ មិនដែលលឺចេះនិយាយអីទេ អាកែវហើយ ក៏កាក អាកែវហើយ ក៏កាកដឹងចេះនិយាយ។

ក៖ មិនដឹងថាវារៀនតាមយើងអត់?

ខ៖ ហ្នឹងឯង។

ក៖ កាកហើយបានន័យថា កែវហ៊ឺយថាតាមយើង ឬក៏យ៉ាងមិច?

ខ៖ ហ្នឹងឯង។

ក៖ ហើយដង្កូវនៀងធ្លាប់ចិញ្ចឹមទេ?

ខ៖ អូ! អត់ អត់ដែលមានចិញ្ចឹមទេ មានតែម្ដាយ។

ក៖ អូ! ម្ដាយធ្លាប់ចិញ្ចឹម?

ខ៖ បាទ!

ក៖ គាត់ចិញ្ចឹមបានប៉ុន្មានឆ្នាំ?

ខ៖ គាត់ចិញ្ចឹមខាងក្រុមសូត្រ ទៅគាត់ចិញ្ចឹមដង្កូវនៀង ចិញ្ចឹមធ្វើសូត្រ។

ក៖ បាទ!

ខ៖ ចិញ្ចឹមបានម៉ាជំនាន់ពពតយូរហើយ ដល់ក្រោយៗនេះអត់មានទេ។

ក៖ ចុះឃ្មុំធ្លាប់ចិញ្ចឹមទេ?

ខ៖ អត់ផង! បានតែយក។

ក៖ ទៅយកនៅឯណាបាន?

ខ៖ ហ៊ឺ! សព្វថ្ងៃអត់មានទេ។

ក៖ តាំងពីក្មេងមកដល់ឥឡូវ មាធ្លាប់មានបញ្ហាណាប្រឈមទេ? ដែលលំបាកខ្លាំងអញ្ចឹងណា?

ខ៖ ប្រឈមមុខច្បាប់ ឬក៏ប្រឈមគ្រាន់តែទើសទែងគ្នា?

ក៖ បានដោះស្រាយនៅ?

ខ៖ ប្រឈមហ្នឹងមុខច្បាប់ធំដែរ គ្រាន់តែមិនសម្រេច លែងលះផ្លូវអីទៅតិចតួច ក៏គេដោះស្រាយអោយទៅ នៅជិតទល់សព្វថ្ងៃទៅ។

ក៖ បាទ! នៅជិតអញ្ចឹងទៅ?

ខ៖ ហ៊ឹ!

ក៖ ពេលវេលាអ្នកកំណត់ទៅណោះ?

ខ៖ ហ្នឹងឯង។

ក៖ ទាក់ទង និងបទពិសោធន៍ល្អៗ មានទេ?

ខ៖ បទពិសោធន៍នៅក្នុងភូមិយើង សម្រាប់ដឹកនាំបងប្អូនប្រជាពលរដ្ឋអោយល្អច្រើន អោយមានបានដល់សព្វថ្ងៃនេះ ដំណើរការក៏បានល្អតលាស់ ដូចជាសាលារៀន ដូចជាសាលាធម្មទានគឺកើតដោយសារពួកខ្ញុំបី បួននាក់។ ដូចថា ជាបង្គោលសម្រាប់បង្គោល សម្រាប់អូសទាញអោយធ្វើ។

ក៖ បាទ! អរគុណ។ អញ្ចឹងកាលពីនៅក្មេង មាធ្លាប់គិតថា ធំឡើងចង់ធ្វើអីទេ?

ខ៖ កាលពីនៅក្មេង?

ក៖ បាទ! ធំឡើងធ្លាប់ស្រមៃថា ធំឡើងចង់ធ្វើអីទេ?

ខ៖ ចង់ដែរ! ដូចថា មិនចង់ធ្វើនៅស្រែ ចំការទេ ចង់ធ្វើការងារមន្ត្រីរាជការ។

ក៖ បាទ!

ខ៖ កាលពីក្មេងណា៎!

ក៖ បាទ!

ខ៖ គ្រាន់ថាសុភាពការវាមិនអំណោយផលអោយ។

ក៖ រឿងប្រទេសជាតិណ៎?

ខ៖ រឿងប្រទេសជាតិ។

ក៖ អរគុណមាដែលបានផ្តល់ការសម្ភាស។ ឥឡូវការសម្ភាសបានមកដល់ទីបញ្ចប់ហើយ ប៉ុន្តែមុនបញ្ចប់ដូចខ្ញុំបានជម្រាបខាងដើមថាគោលបំណងរបស់យើង គឺដើម្បីរក្សាទុកប្រវត្តិហ្នឹង ផ្ទាល់ខ្លួនហ្នឹងដល់កូនចៅជំនាន់ក្រោយ។ ពួកខ្ញុំអត់មានគោលបំណងអីផ្សេងទៀត គឺគ្រាន់តែចង់ថែរក្សាប្រវត្តិរូបរបស់យើងអោយវែងឆ្ងាយអញ្ចឹងណា៎?

ខ៖ ហ៊ឺ!

ក៖ បាទ! ជាចុងក្រោយ តើមាមានអីជាសំណូមពរ ឬក៏មតិយោបល់ដល់ក្មេងៗជំនាន់ក្រោយទេ?

ខ៖ សំណូមពរអី?

ក៖ ចង់អោយពួកគេយ៉ាងមិច?

ខ៖ ចង់អោយតែពួកគេ ការរៀនសូត្រអោយបានលូតលាស់ទៅថ្ងៃអនាគត ប្រទេសជាតិអោយបានរីកចម្រើន រុងរឿងសំបូរសប្បាយ កុំអោយមានការវ៉ឹកវរដូចកាលមួយជំនាន់មុន ប៉ុហ្នឹងឯង។

ក៖ បាទ! (ចប់)